- តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀល ) ពីជំពូក ៥១ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២.**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ផ្តល់ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

**មាត្រា ៣.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីស្តីទី

**ហត្ថលេខា និងត្រា**

**អ៊ុក រ៉ាប៊ុន**

★★★

## អនុក្រឹត្យលេខ ៤៧ អនក្រ.បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគ្រួមប្រឹក្សាយោធា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ១៩៩៩

**សំរេច**

**មាត្រា ១ .–** បង្កើតក្រុមប្រឹក្សាយោធាមួយ ដោយអនុលោមតាមមាត្រាទី ២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ហើយដែលមានសមាសភាព :

- រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងកងទ័ពជើងគោក កងទ័ពជើងអាកាស កងទ័ពជើងទឹក និងកងរាជអាវុធហត្ថ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយអគ្គនាយកដ្ឋានទាំងពីរ នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយស្ថាប័ន អធិការកិច្ច អយ្យការយោធា តុលាការយោធា នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានមួយរូបៗ តំណាងអោយគ្រប់យោធភូមិភាគ និងគ្រប់កងពល សមាជិក
- នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ លេខាធិការ
- នាយកទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ លេខាធិការរង

**មាត្រា ២ .–** ក្រុមប្រឹក្សាយោធានេះ មានភារកិច្ចពិនិត្យ សិក្សា ពិចារណា ដើម្បីរៀបចំសំរួលរាល់លិខិតបទដ្ឋានទាំងឡាយដែលទាក់ទងទៅនឹងបទដ្ឋានយោធា អោយបានសមស្របទៅនឹងច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ មុននឹងធ្វើជូនទៅគណៈរដ្ឋមន្ត្រី សំរេច ។

**មាត្រា ៣ .–** ក្រុមប្រឹក្សាយោធា ត្រូវប្រជុំពិនិត្យស្រាវជ្រាវ និងប្រជុំពេញអង្គ :

- ការប្រជុំពិនិត្យស្រាវជ្រាវប្រព្រឹត្តទៅក្រោមអធិបតីភាពនៃតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ ។
- ការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសំរេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៤ .–** ក្រុមប្រឹក្សាយោធានេះ ត្រូវចូលរួមប្រជុំតាមការកំណត់របស់ប្រធាន ។

- ការប្រព្រឹត្តិទៅ នឹងការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាយោធា ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ជាភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា ៥ ._ ក្នុងករណីក្រសួងការពារជាតិត្រូវដឹកនាំដោយសហរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាននៃក្រុមប្រឹក្សាភិបាលនេះ ។

មាត្រា ៦ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា នឹងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ធៀ បាញ់ ស៊ីសុវត្ថិ សិរីរត្ន

★★★

## អនុក្រឹត្យលេខ ១៤៦ អនក្រ.តត

## ស្តីពីការតម្លើងឋានន្តរសក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

មាត្រា ១ ._ ត្រូវបានតម្លើងឋានន្តរសក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ នាយទាហានអាវុធហត្ថ ដែលមានរាយនាមដូចខាងក្រោម ៖